**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០៤៥ គ.ជ.ប. ស.ណ.ន

# សេចក្ដីណែនាំ

## ស្ដីពី

## ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះនៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

អនុលោមតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ និងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប) សូមជម្រាបជូន **លោក លោកស្រីប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) និងគណបក្សនយោបាយ** ជ្រាបថា ដំណើរការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត បានបញ្ចប់ជាស្ថាពរហើយ ដែលមានគណបក្សនយោបាយចំនួន ១៨ (ដប់ប្រាំបី)។ ដូចនេះ គ.ជ.ប សូមធ្វើការណែនាំដល់ គធ.ខប គឃ.សប និងគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការទាំងអស់អំពីការងារមួយចំនួនដែលត្រូវអនុវត្ត ដូចតទៅ ៖

### ១. ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះនៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត

- គធ.ខប ទាំងអស់ត្រូវចាត់ចែងធ្វើការបិទផ្សាយជាសាធារណៈនូវបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្តរបស់ខ្លួន។ គធ.ខប ត្រូវចាត់ចែងថតចម្លងបន្ថែមនូវបញ្ជីទាំងនេះ ដើម្បីបិទផ្សាយតាមគោលដៅ ដូចខាងក្រោម ៖
  - លេខាធិការដ្ឋាន គធ.ខប ១ (មួយ) ច្បាប់
  - តាមទីប្រជុំជនធំៗមួយចំនួន។
- កាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការត្រូវធ្វើចាប់ពី**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣** ជាតំណត។
- គធ.ខប ទាំងអស់ត្រូវជូនដំណឹងដល់គ្រប់ គឃ.សប អំពីកាលបរិច្ឆេទនៃការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយដូចកំណត់ក្នុងចំណុចទី ២ ខាងក្រោម។

## ២. ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សង្កេតការណ៍តាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តណាមួយមានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ចំនួន១(មួយ)រូប និងភ្នាក់ងារបម្រុង ចំនួន១(មួយ)រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់។
- កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយមានរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ **គឺចាប់ផ្ដើមនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ បញ្ចប់នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣**។
- គណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គឃ.សប រៀងរាល់ម៉ោងធ្វើការ **ពេលព្រឹកចាប់ពីម៉ោង ៧ : ០០ (ប្រាំពីរ) ដល់ម៉ោង ១១ : ៣០ (ដប់មួយសាមសិប) នាទី និងពេលរសៀលចាប់ពីម៉ោង ១៤ : ០០ (ដប់បួន) ដល់ម៉ោង ១៧ : ៣០ (ដប់ប្រាំពីរសាមសិប) នាទី**។
- គធ.ខប ទាំងអស់ត្រូវស្នើសុំកិច្ចសហការ និងសម្របសម្រួលជាមួយអាជ្ញាធរដែនដី ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ពាក់ព័ន្ធនឹងការស្នើសុំចេញលិខិតបញ្ជាក់អំពីភាពមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ សម្រាប់បំពេញបែបបទដាក់ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយនៅ គឃ.សប។

**គធ.ខប** ទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីណែនាំនេះជូនដល់**អាជ្ញាធរមានសមត្ថកិច្ច គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ** សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងក្របខណ្ឌរាជធានី ខេត្តរបស់ខ្លួនឱ្យបានទូលំទូលាយ ដើម្បីត្រៀមសហការ និងចូលរួមអនុវត្តតាមភារកិច្ចរៀងៗខ្លួនស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។

គ.ជ.ប សង្ឃឹមទុកជាមុនថា គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់នឹងយកចិត្តទុកដាក់សហការឱ្យបានល្អ ដើម្បីជំរុញឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**ចម្លងជូន:**

- ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
- ឯកសារ កាលប្បវត្តិ